# សិទ្ធិទទួល ព័ត៌មាន



មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែកក្កដា ឆ្នាំ២០២១

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃអង្គការផ្លាស់ប្តូរសេរីភាពខាងការបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពខាងការបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃសម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ (CIVICUS) ព្រមទាំងជាសមាជិកអង្គការប្រឆាំងទារុណកម្មពិភពលោក ( OMCT SOSTorture Network) និងជាសមាជិក OECD Watch ផងដែរ។

គេហទំព័ររបស់សិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិនិងសេរីភាព" និងទទួលពានរង្វាន់ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនងនិងផ្លាស់ប្តូរសង្គម នៅសកលវិទ្យាល័យឃ្វីនឡែនទីក្រុងប្រ៊ីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។

## សេចក្តីថ្លែងអំណរគុណ

ម.ស.ម.ក សូមថ្លែងអំណរគុណចំពោះអង្គការដៃគូ ស្ថាប័នផ្សព្វផ្សាយ និងជាពិសេសយុវជនមកពីមជ្ឈដ្ឋានផ្សេងៗគ្នា ដែលបានចូលរួមក្នុងកិច្ចពិភាក្សាក្រុមទាំងផ្ទាល់ និងអនឡាញ និងបានផ្តល់នូវធាតុចូលដ៏មានសារសំខាន់ដើម្បីកំណត់នូវប្រធានបទទាក់ទងនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។

## អំពីមេរៀនស្តីពីសិទ្ធិទទួលព័ត៌មាន

មេរៀនស្តីពីសិទ្ធិទទួលព័ត៌មាន ("មេរៀន") តាក់តែងឡើងជាផ្នែកមួយនៃគម្រោងលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា ក្នុងគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងដល់ពលរដ្ឋអំពីសិទ្ធិទទួលព័ត៌មាននៅប្រទេសកម្ពុជា។ មេរៀននេះនឹងលើកឡើងនូវនិយមន័យនៃសិទ្ធិទទួលព័ត៌មាន និងសិទ្ធិក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន ព្រមទាំងបកស្រាយបញ្ជាក់នូវច្បាប់ដែលត្រូវអនុវត្ត រួមមានច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិចំពោះសិទ្ធិទទួលព័ត៌មានផងដែរ។

មេរៀននេះក៏ពិភាក្សាអំពីកាតព្វកិច្ចរបស់រដ្ឋក្នុងការលើកកម្ពស់សិទ្ធិបុគ្គលគ្រប់រូបក្នុងការទទួលព័ត៌មាន ដោយគូសបញ្ជាក់អំពីព័ត៌មានដែលត្រូវតែផ្តល់ជូនសាធារណជន និងពិភាក្សាអំពីករណីលើក

លែងចំពោះការបង្ហាញព័ត៌មាន។ បន្ថែមពីលើនេះទៀត មេរៀននេះក៏បានបង្ហាញអំពីសារៈសំខាន់នៃការទទួលព័ត៌មានសម្រាប់ប្រជាពលរដ្ឋផងដែរ។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមទាក់ទងនឹងមេរៀននេះ សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈ៖


អាសយដ្ឋាន៖ ផ្ទះ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

គេហទំព័រ៖ www.cchrcambodia.org



CC BY NC SA

# មាតិកា

១. តើអ្វីទៅជាសិទ្ធិទទួលព័ត៌មាន? ........ ១
១.១. សិទ្ធិក្នុងការស្វែងរកព័ត៌មាន ........ ១
១.២. សិទ្ធិក្នុងការទទួលព័ត៌មាន ........ ១
១.៣. សិទ្ធិក្នុងការផ្សព្វផ្សាយព័ត៌មាន ........ ១
២.ក្របខណ្ឌច្បាប់........ ១
២.១. ច្បាប់ជាតិ........ ១
២.២. ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ........ ២
៣.កាតព្វកិច្ចរបស់រដ្ឋចំពោះសិទ្ធិទទួលព័ត៌មាន ........ ៣
៤.តើព័ត៌មានអ្វីដែលអាចទទួលបាន? ........ ៤
៤.១. ការលើកលែងចំពោះការបង្ហាញព័ត៌មាន........ ៦
៥.សារៈសំខាន់ និងមុខងារក្នុងការទទួលព័ត៌មាន ........ ៨

# សិទ្ធិទទួលព័ត៌មាន

## ១. តើអ្វីទៅជាសិទ្ធិទទួលព័ត៌មាន?

សិទ្ធិទទួលព័ត៌មាន គឺជាផ្នែកមួយនៃសេរីភាពខាងការបញ្ចេញមតិ។ សិទ្ធិទទួលព័ត៌មានគឺជាលទ្ធភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មានប្រកបដោយប្រសិទ្ធិភាព។

### ១.១. សិទ្ធិក្នុងការស្វែងរកព័ត៌មាន



សិទ្ធិក្នុងការស្វែងរកព័ត៌មាន គឺជាសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការទទួលបានព័ត៌មានទូទៅ និងជាពិសេសទៅទៀតនោះគឺព័ត៌មានដែលទាក់ទងនឹងផលប្រយោជន៍សាធារណៈ ដែលអាចជាចំណែកក្នុងការជជែកពិភាក្សាជាសាធារណៈ។

### ១.២. សិទ្ធិក្នុងការទទួលព័ត៌មាន

សិទ្ធិក្នុងការទទួលព័ត៌មាន ជាក់ស្តែងមិនមែនត្រឹមតែសាធារណជនទទួលខុសត្រូវក្នុងការស្នើសុំព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែស្ថាប័នរដ្ឋផ្ទាល់ទៀតសោធ ត្រូវតែសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានឱ្យទូលំទូលាយទាក់ទងនឹងផលប្រយោជន៍សាធារណៈ។

### ១.៣. សិទ្ធិក្នុងការផ្សព្វផ្សាយព័ត៌មាន

សិទ្ធិក្នុងការផ្សព្វផ្សាយព័ត៌មានរួមមាន សិទ្ធិក្នុងការចែករំលែក និងចែកចាយព័ត៌មានផ្សេងៗ។

## ២.ក្របខណ្ឌច្បាប់

សិទ្ធិទទួលព័ត៌មានត្រូវបានគាំពារទាំងច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដើម្បីធានាថាសាធារណជនអាចទទួលព័ត៌មាន។

### ២.១. ច្បាប់ជាតិ

នៅក្នុងមាត្រា ៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស នៅក្នុងន័យនេះ សិទ្ធិទទួលព័ត៌មានត្រូវបានការពារទាំងច្បាប់ជាតិ និងច្បាប់ អន្តរជាតិ។[1] ឧទាហរណ៍នៅក្នុងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងថា ពលរដ្ឋខ្មែរគ្រប់រូបត្រូវបានធានាថាមានសិទ្ធិខាងការបញ្ចេញមតិនូវរាល់គំនិតរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសិទ្ធិខាងការជួបប្រជុំ។[2]

[1] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[2] មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៥ នៃច្បាប់ស្តីពីរបបសារព័ត៌មាននៅកម្ពុជា ក៏មានចែងអំពីសារព័ត៌មាន មានសិទ្ធិទទួលព័ត៌មាន ដែលស្ថិតក្នុងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល។[3]

បន្ថែមលើនេះទៀត សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅក្នុងប្រទេសកម្ពុជានាពេលថ្មីៗនេះ ដែលក្នុងនោះមាត្រា៥ នៃសេចក្តីព្រាងច្បាប់នេះបានចែងអំពីសិទ្ធិទទួលព័ត៌មាន និងធានាថាបុគ្គលគ្រប់រូបមានសិទ្ធិទទួលព័ត៌មាន ដែលគ្រប់គ្រងដោយស្ថាប័នសាធារណៈ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ។[4]

## ២.២. ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

នៅក្នុងមាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថា "មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។[5]

បន្ថែមលើនេះទៀត មាត្រា១៩ កថាខណ្ឌទី២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងថា "ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាព ស្វែងរកព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។[6]

ដូច្នេះសិទ្ធិទទួលព័ត៌មានដែលស្ថិតនៅក្រោមច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិបានធានាដល់មនុស្សគ្រប់រូបនូវសិទ្ធិទទួលបាននូវរាល់ព័ត៌មាន និងឯកសារផ្សេងៗ ដែលទាក់ទងនឹងការគ្រប់គ្រងកិច្ចការសាធារណៈ ដោយមិនគិតពីស្ថានភាពរបស់បុគ្គលដែលពាក់ព័ន្ធនឹងគោលបំណងដើម្បីទទួលព័ត៌មានដែលត្រូវការ។

[3] មាត្រា ៥ នៃច្បាប់ស្តីពីរបបសារព័ត៌មាន

[4] មាត្រា ៥ នៃសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

[5] មាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

[6] មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

## ៣.ភាតព្វកិច្ចរបស់រដ្ឋចំពោះសិទ្ធិទទួលព័ត៌មាន



ដើម្បីឱ្យសិទ្ធិទទួលព័ត៌មានមានប្រសិទ្ធិភាព មាត្រា១៩ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តម្រូវឱ្យរដ្ឋភាគីគួរតែសកម្មក្នុងការដាក់បញ្ចូលជាសាធារណៈនូវព័ត៌មានរបស់រដ្ឋាភិបាល ដែលជាផលប្រយោជន៍សាធារណៈ និងធានាបាននូវភាពងាយស្រួល រហ័ស មានប្រសិទ្ធិភាព ក្នុងការទទួលព័ត៌មានទាំងនេះ។ រដ្ឋភាគីគួរតែអនុម័តនូវនីតិវិធីដ៏ចាំបាច់នានា ដែលធ្វើឱ្យប្រសើរឡើងនៃសិទ្ធិទទួលព័ត៌មាន។ នីតិវិធីនៃដំណើរការស្នើសុំព័ត៌មានមានភាពឆាប់រហ័ស ដែលយោងតាមវិធានថ្នាក់ជាតិច្បាស់លាស់ ហើយសមស្របទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ លើសពីនេះទៅទៀត ថ្លៃសេវាសម្រាប់ការស្នើសុំព័ត៌មានផ្សេងៗ មិនត្រូវមានតម្លៃខ្ពស់ ដែលអាចជាឧបសគ្គមិនសមហេតុផលមួយក្នុងការទទួលបានព័ត៌មានឡើយ។ អាជ្ញាធរក៏មានកាតព្វកិច្ចក្នុងការផ្តល់នូវហេតុផលផ្សេងៗចំពោះការបដិសេធមិនផ្តល់ព័ត៌មាន ហើយយន្តការបណ្តឹង គួរតែត្រូវបានធ្វើឡើងសម្រាប់ការបដិសេធចំពោះសិទ្ធិទទួលព័ត៌មានក៏ដូចជាក្នុងករណីខកខានមិនបានឆ្លើយតបនឹងសំណើរបស់ពលរដ្ឋ។[7]

[7] សេចក្តីពន្យល់ទូទៅលេខ ៣៤ របស់គណៈកម្មាការសិទ្ធិមនុស្ស អ.ស.ប (២០១១) កថាខណ្ឌទី ១៩

ចំពោះស្ថាប័នសាធារណៈក្រោមមាត្រា ៨ និងមាត្រា ៩ នៃសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវ អនុវត្តកាតព្វកិច្ចដូចខាងក្រោម ដើម្បីសម្រួលដល់ការទទួលព័ត៌មាន[៦]៖

១. បង្កើតការិយាល័យព័ត៌មាននៅតាមស្ថាប័នរដ្ឋនីមួយៗទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

២. បណ្តុះបណ្តាលមន្ត្រីដែលទទួលបន្ទុកព័ត៌មានឱ្យមានសមត្ថភាពជំនាញអំពីសិទ្ធិទទួលព័ត៌មាន

៣. ជំរុញអង្គភាពជំនាញចំណុះឱ្យស្ថាប័នសាម៉ី ត្រូវសហការទទួលខុសត្រូវក្នុងការស្រាវជ្រាវ និងផ្តល់ ព័ត៌មានដល់អ្នកស្នើសុំ

៤. ជួយសម្រួលដល់បុគ្គលគ្រប់រូប ដែលស្នើសុំព័ត៌មាន និង

៥. ផ្តល់ជូននូវរាល់ព័ត៌មានដែលបានស្នើសុំទាំងអស់ដល់សាធារណជន។

## ៤.តើព័ត៌មានអ្វីដែលអាចទទួលបាន?

រដ្ឋាភិបាលកាន់កាប់ព័ត៌មានមិនមែនត្រឹមតែសម្រាប់ខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែផ្ទុយទៅវិញគឺតំណាងឱ្យសាធារណជនទាំងមូល។ សម្រាប់ហេតុផលនេះ ស្ថាប័នសាធារណៈគួរតែផ្តល់នូវសិទ្ធិទទួលព័ត៌មាន។ ដោយយោងទៅតាមគោលការណ៍នៃការបង្ហាញជាអតិបរិមា សិទ្ធិរបស់ពលរដ្ឋដើម្បីទទួលព័ត៌មានអនុវត្តទៅលើរាល់ព័ត៌មានទាំងអស់ដែលស្ថិតក្រោមកម្មសិទ្ធិ ការរក្សាទុក ឬការគ្រប់គ្រងដោយអង្គភាពសាធារណៈ។ ពលរដ្ឋអាចស្នើសុំការទទួលព័ត៌មានណាមួយដោយមិនគិតអំពីស្ថានភាព ផល

[៦] មាត្រា ៨ និង៩ នៃសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

ប្រយោជន៍ការទទួលព័ត៌មាន ឬទំនាក់ទំនងរបស់ពួកគេទៅនឹងព័ត៌មាននោះ ហើយពួកគេអាចស្នើសុំការទទួលព័ត៌មានដែលពួកគេជ្រើសរើស។ ពួកគេមិនត្រូវបានចោទសួរនៅពេលធ្វើការស្នើសុំនោះទេ មិនថាស្វែងរកព័ត៌មានប្រភេទណាក៏ដោយ។[៩] ទោះយ៉ាងណាក៏ដោយ ទាំងអស់នេះមិនមានន័យថារដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការផ្តល់ជូនគ្រប់យ៉ាងដែលពលរដ្ឋអាចស្នើសុំបាននោះទេ។ ទាំងនេះនឹងពិភាក្សាបន្ថែមទៀតនៅផ្នែកបន្ទាប់។ នៅក្នុងន័យនេះ ពលរដ្ឋអាចស្នើសុំក្នុងការទទួលបានព័ត៌មានរួមមាន៖



១ ការរៀបចំ និងដំណើរការទាំងអស់នៃស្ថាប័នសាធារណៈ

២ ផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងគ្រប់វិស័យរបស់ស្ថាប័នសាធារណៈ

៣ ព័ត៌មានលម្អិតអំពីយន្តការសេវាកម្ម

៤ ច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ សេចក្តីសម្រេច និងភារកិច្ចរបស់ស្ថាប័នសាធារណៈទាក់ទងទៅនឹងសិទ្ធិ សេរីភាព កាតព្វកិច្ច និងផលប្រយោជន៍សាធារណៈ

[៩] អង្គការមាត្រា១៩ សិទ្ធិទទួលបានព័ត៌មាន ទំព័រទី១ (២០១៨)

៥ គ្រប់ទិដ្ឋភាពទាំងអស់នៃស្ថាប័នសាធារណៈដែលមានដំណើរការ និងនីតិវិធីនៅតុលាការ រួមទាំងកិច្ចការរដ្ឋបាលដែលជាប្រយោជន៍ ហើយមានទំនាក់ទំនងផ្ទាល់ជាមួយសាធារណជន និង

៦ ផែនការថវិកាប្រចាំឆ្នាំរបស់ស្ថាប័ន ដែលអនុម័តដោយអង្គនីតិប្បញ្ញត្តិ និងរបាយការណ៍ចំណាយ និង សាវនកម្មប្រចាំឆ្នាំ។

## ៤.១. ការលើកលែងចំពោះការបង្ហាញព័ត៌មាន

ការថ្លឹងថ្លែងមានបីជំហានដែលមានចែងក្នុងមាត្រា១៩ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជួយក្នុងការវាយតម្លៃភាពដែលអាចទទួលយកបាននៃការរឹតត្បិត។ នៅពេលដែលនិយាយអំពីសិទ្ធិទទួលព័ត៌មាន ការប្រើប្រាស់ការថ្លឹងថ្លែងជាបីជំហាននឹងជួយកំណត់ថា តើការបដិសេធរបស់អាជ្ញាធរក្នុងការចែករំលែកព័ត៌មានគឺជាការរឹតត្បិតសិទ្ធិក្នុងការទទួលព័ត៌មាន និងសេរីភាពខាងការបញ្ចេញមតិ ឬផ្ទុយទៅវិញនេះមិនមែនជាការហាមឃាត់ ដែលអាចធ្វើទៅបានទេ ដូច្នេះគឺចាត់ទុកថាជាការរំលោភលើសេរីភាពខាងការបញ្ចេញមតិ។ ការធ្វើការសាកល្បងទាំងបីជំហាននេះមានដូចខាងក្រោម៖

**ជំហានទី១ ក្របខណ្ឌច្បាប់៖** តើការរឹតត្បិតមានចែងក្នុងច្បាប់ដែរឬទេ ?

**ជំហានទី២ ភាពស្របច្បាប់៖** តើការរឹតត្បិតដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ពោលគឺ ១) ការគោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ២) ការការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ដែរទេ ?

**ជំហានទី៣ ភាពចាំបាច់៖** តើការរឹតត្បិតមានភាពចាំបាច់ក្នុងការសម្រេចគោលបំណងមានលក្ខណៈស្របច្បាប់ដែលបានកំណត់នៅក្នុងជំហានទី ២ ដែរទេ ?



ឧទាហរណ៍៖ លោក ក គាត់ចង់ទទួលព័ត៌មានដែលទាក់ទងនឹងការរីករាលដាលនៃជំងឺកូវីដ១៩ នៅប្រទេសកម្ពុជាពីក្រសួងសុខាភិបាល។ គាត់ចង់ដឹងថាតើមានអ្នកជំងឺប៉ុន្មានអ្នក និងទីតាំងនៃការឆ្លងបានកើតឡើង។ ប្រសិនក្រសួងសុខាភិបាលបដិសេធមិនផ្តល់ព័ត៌មាននេះដល់គាត់ទេ នេះជាការរឹតត្បិតសិទ្ធិរបស់លោក ក ក្នុងការទទួលព័ត៌មាន។ ទោះជាយ៉ាងណាក៏ដោយ ការរឹតត្បិតនេះអាចអនុញ្ញាតបាន ប្រសិនបើអនុលោមតាមការសាកល្បងទាំងបីជំហានដែលមានចែងនៅក្នុងមាត្រា១៩ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖

ជំហានទី១ ក្របខណ្ឌច្បាប់៖ តើមានបទប្បញ្ញត្តិច្បាប់ណាមួយដែលអនុញ្ញាតឱ្យក្រសួងសុខាភិបាលក្នុងការដកហូតនូវព័ត៌មានប្រភេទនេះបាន? ប្រសិនបើចម្លើយថាបាទ/ចាស យើងអាចបន្តទៅជំហានទី២។ ប៉ុន្តែប្រសិនបើចម្លើយថាទេ នោះមិនមានអនុលោមតាមការថ្លឹងថ្លែងដែលមានទាំងបីជំហាននេះទេ ហើយការរឹតត្បិតមិនត្រូវបានអនុញ្ញាត នោះមានន័យថាជាការរំលោភបំពានសិទ្ធិរបស់លោក ក ក្នុងការទទួលព័ត៌មាន។

ជំហានទី២ ភាពស្របច្បាប់៖ តើការសម្រេចចិត្តរបស់ក្រសួងក្នុងការដកហូតព័ត៌មានជាការសមហេតុសមផល ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ដែរឬទេ? ផលប្រយោជន៍ស្របច្បាប់នេះត្រូវបានកំណត់នៅក្នុងមាត្រា១៩ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ ១) ការគោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឬ២) ការការពារចំពោះសន្តិសុខជាតិឬ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌។ ប្រសិនបើចម្លើយគឺបាទ/ចាស ដែលការរឹតត្បិតនេះការពារផលប្រយោជន៍ស្របច្បាប់យើងអាចបន្តទៅជំហានទី៣។ ប្រសិនបើចម្លើយគឺទេ នោះមានន័យថាការរឹតត្បិតមិនអាចការពារដល់ផលប្រយោជន៍ស្របច្បាប់ ហើយមិនអនុលោមតាមការថ្លឹងថ្លែងទាំងបីជំហាននោះទេ ហើយការរឹតត្បិតនេះគឺមិនអាចអនុញ្ញាតបានទេ មានន័យថានេះគឺជាការរំលោភបំពានសិទ្ធិរបស់លោក ក ក្នុងការទទួលព័ត៌មាន។

ជំហានទី៣ ភាពចាំបាច់៖ តើការសម្រេចចិត្តរបស់ក្រសួងក្នុងការដកហូតព័ត៌មានចំបាច់ដែរឬទេ ដើម្បីសម្រេចបាននូវគោលបំណងមានលក្ខណៈស្របច្បាប់ដែលបានកំណត់នៅក្នុងជំហានទី២? តើការសម្រេចចិត្តនេះគឺជាវិធានការតឹងរ៉ឹងបំផុតដើម្បីទទួលបានគោលបំណងស្របច្បាប់នេះដែរឬទេ? ប្រសិនបើចម្លើយបាទ/ចាស នោះការសម្រេចចិត្តរបស់ក្រសួងក្នុងការដកហូតព័ត៌មាន គឺចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងស្របច្បាប់ហើយថានេះពិតជាវិធានការដែលមានកម្រិតតិចតួចបំផុត គឺមានការអនុលោមតាមការថ្លឹងថ្លែងទាំងបីជំហាន

មានន័យថាការរឹតត្បិតអាចអនុញ្ញាតបាន៖ ក្រសួងត្រូវបានអនុញ្ញាតក្នុងការបដិសេធចំពោះការសម្រេចចិត្តមិនផ្ដល់ព័ត៌មាន។ ប្រសិនបើចម្លើយគឺទេ នោះការសម្រេចចិត្តរបស់ក្រសួងមិនមានភាពចាំបាច់ ដើម្បីសម្រេចបាននូវគោលបំណងស្របច្បាប់ទេ ឬនេះមិនមែនជាវិធានការរឹតត្បិត ដែលអាចសម្រេចគោលបំណងនេះបាន នោះបញ្ជាក់ថាមិនអនុលោមតាមការការថ្លឹងថ្លែងទាំងបីជំហានហើយការរឹតត្បិតក៏មិនអាចអនុញ្ញាតបានមានន័យថាគឺជាការរំលោភលើសិទ្ធិរបស់លោក ក ក្នុងការទទួលព័ត៌មាន។

## ៥.សារៈសំខាន់ និងមុខងារក្នុងការទទួលព័ត៌មាន



ការទទួលព័ត៌មានអាចឱ្យប្រជាពលរដ្ឋទាំងអស់បានយល់ដឹងដូចខាងក្រោម៖

☞ តើត្រូវធ្វើការសម្រេចចិត្តយ៉ាងណានៅពេលសេចក្ដីសម្រេចចិត្តរបស់រដ្ឋប៉ះពាល់ដល់ពួកគេ

☞ ថាតើមូលនិធិសាធារណៈត្រូវបានប្រើប្រាស់យ៉ាងដូចម្ដេច ហើយការប្រើប្រាស់នោះយោងទៅតាមលក្ខខណ្ឌ ដែលបានចែងក្នុងស្ថាប័នយ៉ាងដូចម្ដេចខ្លះ?

☞ ហើយក្នុងនោះក៏អនុញ្ញាតឱ្យអង្គការសង្គមស៊ីវិលទទួលព័ត៌មានដែលចាំបាច់ ដើម្បីអភិវឌ្ឍកម្មវិធី និងយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពនិងអនុវត្តតួនាទីរបស់ខ្លួនជាអ្នកឃ្លាំមើលប្រកបដោយប្រសិទ្ធភាពផងដែរ

☞ ជួយឱ្យបុគ្គលធ្វើការសម្រេចចិត្តដោយផ្អែកលើទិន្នន័យត្រឹមត្រូវ ដែលជាលក្ខខណ្ឌចាំបាច់ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងការគ្រប់គ្រងថវិកាសាធារណៈដែលមិនត្រឹមត្រូវ

☞ ក្នុងនោះដែរក៏ជួយឱ្យបុគ្គលចូលរួមវិភាគទានយ៉ាងសកម្មក្នុងការស្រាវជ្រាវបែបវិទ្យាសាស្ត្រ និងរួមចំណែកដល់ការជំរុញផ្នែកពាណិជ្ជកម្ម និងការបង្កើតភាពរឹងមាំចំពោះវិស័យសេដ្ឋកិច្ច និង

☞ អ្វីដែលសំខាន់បំផុតនោះ គឺតាមដានការរំលោភសិទ្ធិពលរដ្ឋ ព្រមទាំងបង្កើត និងគាំទ្រការអនុវត្តបែបប្រជាធិបតេយ្យ និងការចូលរួមនៃអភិបាលកិច្ចផងដែរ។[10]

----**ចប់**----

[10] អង្គការមាត្រា១៩, សិទ្ធិទទួលបានព័ត៌មាន ទំព័រទី១ (២០១៨)